# ៤ - ទីស្ដីការរដ្ឋមន្ត្រីក្រសួងអប់រំ យុវជន និងកីឡា

## ប្រកាស

ភ្នំពេញ ,ថ្ងៃទី ០៤ ខែ មករា ឆ្នាំ ១៩៩៥

**ប្រកាសលេខ ១៤ អសក. ប្រក**

**ស្ដីពីការផ្ទេរសាលាបឋមសិក្សា ពី ស្រុកកំពត និងស្រុកកំពង់ត្រាច ខេត្តកំពតអោយស្ថិតនៅ ក្រោមការគ្រប់គ្រង របស់មន្ទីរ អប់រំយុវជននិងកីឡា ក្រុងកែប**

* * *

រដ្ឋមន្ត្រី ក្រសួងអប់រំយុវជននិងកីឡា

- បានឃើញ រដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យ ព្រះបាទសម្ដេច **នរោត្តម សីហនុវរ្ម័ន** ព្រះមហាក្សត្រ នៃព្រះរាជាណាចក្រកម្ពុជា ចុះថ្ងៃទី ០១-១១-៩៣ ស្ដីពីការតែងតាំងរដ្ឋាភិបាល
- បានឃើញ ច្បាប់ស្ដីពីការរៀបចំ និងការប្រព្រឹត្តិទៅនៃគណៈរដ្ឋមន្ត្រី ដែលប្រកាសអោយប្រើដោយព្រះរាជក្រម ចុះថ្ងៃទី ២០-៧-៩៤
- បានឃើញ ក្រឹត្យច្បាប់លេខ ៣០ ក្រ.ច ចុះថ្ងៃទី ២០-១១-៩៦ ស្ដីពីប្រព័ន្ធអប់រំចំនេះទូទៅ
- បានឃើញអនុក្រឹត្យលេខ ១៩ អនក្រ ចុះថ្ងៃទី ២៥ តុលា ១៩៨៦ ស្ដីពីការកំនត់បទដ្ឋានប្រើប្រាស់ក្របខ័ណ្ឌ សំរាប់អង្គភាពអប់រំនានា
- បានពិនិត្យលិខិតស្នើសុំ របស់មន្ទីរអប់រំ យុវជន និងកីឡាខេត្តកំពតលេខ ១០២អយកខ ចទម ចុះថ្ងៃទី ០៨ កញ្ញា ឆ្នាំ ១៩៩៥
- តាមយោបល់ឯកភាព របស់នាយកដ្ឋាន ចំនេះទូទៅ និង មត្តេយ្យសិក្សា

**សំរេច**

**ប្រការ ១ :** អនុញ្ញាតអោយ មន្ទីរអប់រំយុវជន និង កីឡា ខេត្តកំពត ផ្ទេរសាលាបឋមសិក្សាចំនួន ៧ ខាងក្រោមនេះ អោយមន្ទីរអប់រំយុវជន និង កីឡាក្រុងកែបគ្រប់គ្រងវិញចាប់ពីឆ្នាំសិក្សា ១៩៩៥--១៩៩៦ នេះតទៅ

១-សាលាបឋមសិក្សាថិយាវង្ស នៅសង្កាត់អូរក្រសារ ក្នុងស្រុកកំពត

២-សាលាបឋមសិក្សា ភ្នំសរសៀ នៅសង្កាត់ អូរក្រសារ ក្នុងស្រុកកំពត

៣-សាលាបឋមសិក្សា ពងទឹក នៅសង្កាត់ ពងទឹក ក្នុងស្រុក កំពង់ត្រាច

៤-សាលាបឋមសិក្សា ព្រៃតាកុយ នៅសង្កាត់ពងទឹក ក្នុងស្រុកកំពង់ត្រាច

៥-សាលាបឋមសិក្សា ភ្នំលាវ នៅសង្កាត់ពងទឹក ក្នុងស្រុក កំពង់ត្រាច

៦-សាលាបឋមសិក្សា អង្កោល នៅសង្កាត់អង្កោល ក្នុងស្រុក កំពង់ត្រាច

៧-សាលាបឋមសិក្សា ព្រៃកតាទេន នៅសង្កាត់អង្កោល ក្នុងស្រុកកំពង់ត្រាច

**ប្រការ ២ :** នាយក នាយករង ដែលគ្រប់គ្រងសាលាទាំង ៧ ខាងលើនេះ ត្រូវស្ថិតនៅក្រោមការគ្រប់គ្រង របស់មន្ទីរអប់រំយុវជន និង កីឡាក្រុងកែប ។

**ប្រការ ៣ :** បុគ្គលិកទាំងអស់ដែលបំរើការងារ នៅសាលាបឋមសិក្សាទាំង ៧ ខាងលើនេះត្រូវស្ថិតនៅក្រោមការគ្រប់គ្រង របស់មន្ទីរអប់រំយុវជន និង កីឡាក្រុងកែប ។

**ប្រការ ៤ :** បទបញ្ញត្តិទាំងឡាយណា ដែលមានខ្លឹមសារផ្ទុយពីប្រកាសនេះត្រូវចាត់ទុកជានិរាករណ៍ ។

**ប្រការ ៥ :** ប្រធានមន្ទីរក្រសួងអប់រំយុវជន និងកីឡា ប្រធាននាយកដ្ឋានចាត់តាំង ប្រធាននាយកដ្ឋានផែនការហិរញ្ញកិច្ច ប្រធាននាយកដ្ឋានចំនេះទូទៅ និង មត្តេយ្យសិក្សាប្រធាននាយកដ្ឋាន ប្រធានមន្ទីរអប់រំយុវជន និង កីឡា ខេត្តកំពត ប្រធានមន្ទីរអប់រំយុវជន និងកីឡាក្រុងកែប ប្រធានការិយាល័យអប់រំយុវជន និងកីឡាស្រុកកំពត ប្រធានការិយាល័យអប់រំយុវជន និង កីឡាស្រុកកំពង់ត្រាច នាយកសាលាបឋមសិក្សាវត្តថិយាវង្ស នាយកសាលាបឋមសិក្សា ភ្នំសរសៀ នាយកសាលាបឋមសិក្សា ពងទឹក នាយកសាលាបឋមសិក្សា ព្រៃតាកុយ នាយក សាលាបឋមសិក្សាភ្នំលាវ នាយកសាលាបឋមសីក្សាអង្កោល នាយកសាលាបឋមសិក្សា ព្រៃកតាទេន មានភារកិច្ចអនុវត្តប្រកាសនេះ ។

**រដ្ឋមន្ត្រី**

**ហង្សលេខា និង ត្រា**

**តុលា ឡោះ**